## ការសាកល្បងសិក្សា

# ធាតុ នៃព្រឹត្តការណ៍ ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០

ជាបឋម យើង យល់ឃើញថា ព្រឹត្តការណ៍ ១៨មិនា ឆ្នាំ ១៩៧០ មិនមែនជា បដិវត្តន៍ នោះឡើយ ព្រោះ វាកើតឡើង ដោយមានច្បាប់ ជាមូលដ្ឋាន ដែលយើង សាកល្បង ធ្វើវិភាគ ជាគតិយុត្ត ដូចខាងក្រោមនេះ។

តែយើងគួរពិចារណាដែរ អំពីធាតុនៃបដិវត្តន៍ ទុកជា គំនិតទូទៅ។ យើងដឹងថា បដិវត្តន៍មានធាតុពីរយ៉ាង៖ បដិវត្តន៍ នយោបាយ និង បដិវត្តន៍ សង្គម តែបដិវត្តន៍ ទាំងពីរ នេះ ទី១ អាចនាំមក នូវការប្តូរ គ្រោងសង្គម ហើយ ទី២ អាចនាំមក នូវការប្តូរ របបនយោបាយ។ ឧទាហរណ៍ ៖ បដិវត្តន៍ បារាំង ក្នុងឆ្នាំ ១៧៨៩ ជា បដិវត្តន៍ សង្គម កើតចេញមក ពីប្រជាជនបារាំងទាមទារសេរីភាព នាំឲមាន ការប្តូរ របបនយោបាយចាស់ មកជារបបសាធារណរដ្ឋ ; រីឯ បដិវត្តន៍ នៅប្រទេស រុស្សី វិញ ជាបដិវត្តន៍ នយោបាយ ដឹកនាំដោយចលនានយោបាយ ដើម្បី រំលំរបបរាជានិយម ដើម្បីប្តូរ សង្គមចាស់ មកជា សង្គមកុម្មុយនិស្ត។ តែ ក៏អាចមាន ការប្តូរ គ្រោងសង្គម ឬ របប នយោបាយ ដោយមិនចាំបាច់ យកវិធីបដិវត្តន៍ មកធ្វើជាមធ្យោបាយដែរ។ ការប្តូរបែបនេះ ហៅថា លទ្ធិប្រជាធិបតេយ្យ ដែលមាន ប្រជាពលរដ្ឋ ជាម្ចាស់អំណាច មានសេរីភាពសម្រេចលើ ជោគវាសនា របស់ខ្លួនឯង ដោយខ្លួនឯង។ បដិវត្តន៍ ជាការប្តូរ ដោយប្រើ កម្លាំង រីឯ លទ្ធិប្រជាធិបតេយ្យ វិញ ជាការប្តូរ ដោយប្រើ ចំណូលចិត្ត[1] ដូចមាន នៅក្នុង បដិវត្តន៍ អាមេរិកាំង ដែលគេទុក ជា **អនុបាតុភូត**[2] មួយ អាចប្តូរ សង្គមបានជាជម្រៅ ដោយមិនចាំបាច់ប្រើកម្លាំងហឹង្សា៖ ដូច្នេះ គេអាចដូរ របបនយោបាយ ដោយមិនចាំបាច់ដូរ គ្រោងសង្គម តែ គេក៏អាចដូរ គ្រោងសង្គម ដោយមិនចាំបាច់ដូរ របបនយោបាយ នោះដែរ។ គេអាចឲនិយមន័យរបស់ពាក្យ បដិវត្តន៍ ថាជា **ព្រឹត្តិការណ៍មួយ ដែលមិនដែលមានកើតឡើង តែប៉ុណ្ណោះ** ដោយមិនចាំបាច់ យក បដិវត្តន៍ ដែលធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រ ដូចយ៉ាង បដិវត្តន៍ ម៉ារ្សនិយម ឬ រដ្ឋប្រហារ ជាច្រើន មកធ្វើជា យោង នៃនិយមន័យ នោះឡើយ។ បដិវត្តន៍ពិត មិនមែនជា រដ្ឋប្រហារ, សង្គ្រាមដណ្តើមអំណាច ឬ ការបះបោរ រួចបន្តធ្វើ **សុទ្ធកម្ម**[3], ចាប់ឃុំឃាំងនិងសម្លាប់មនុស្ស ជាយថាហេតុ នោះឡើយ ដូច ពួកកុម្មុយនិស្ត ឬ ពួកអ្នកនិយមអំណាចផ្តាច់ការ គេយកមកធ្វើជា **វិធីប្រតិបត្តិ**[4] របស់គេ។ បដិវត្តន៍ពិតជា ព្រឹត្តិការណ៍មួយ មានកើតឡើង ដើម្បី ស្វែងរក វឌ្ឍនភាព ឲដល់ សង្គម និង ប្រជាពលរដ្ឋ។ គេដឹងថា លទ្ធិកុម្មុយនិស្ត យកពាក្យ បដិវត្តន៍ មកធ្វើជា **ឯកាធិភាព**[5] រួច បញ្ឆោត និងរំលោភ ប្រជាជន ដើម្បី បំរើ ប្រយោជន៍ បក្សកុម្មុយនិស្ត តែប៉ុណ្ណោះ ផ្ទុយនឹង លទ្ធិប្រជាធិបតេយ្យ ទុក ប្រជាពលរដ្ឋ ជាម្ចាស់អំណាច ដែលមានរដ្ឋ ជាឧបករណ៍ របស់ អំណាច បីយ៉ាង៖ នីតិបញ្ញត្តិ, នីតិប្រតិបត្តិ និង តុលាការ។

[1] ចំណូលចិត្ត= Gré។
[2] អនុបាតុភូត= ជាការចម្លែក ; Epiphénomène។
[3] សុទ្ធកម្ម= ការជម្រះ សំអាត ; Epuration។
[4] វិធីប្រតិបត្តិ= Mode opératoire។
[5] ឯកាធិភាព= Monopole។

រដ្ឋ ជាឧបករណ៍ របស់ អំណាច ដែលមានប្រជាពលរដ្ឋ ជាអធិបតី វាផ្ទុយពី រដ្ឋ ជាឧបករណ៍ របស់អំណាច បក្សពួក ប្រើ សំរាប់ **និគ្រោះ**[6] ប្រជាពលរដ្ឋ។ រដ្ឋបែបនេះ ហៅថា អនីតិរដ្ឋ គឺ គ្រាន់តែជា អង្គការ បង្រាប ឬ ជិះជាន់ របស់ អំណាច តែប៉ុណ្ណោះ។

ក្នុងការសាកល្បងសិក្សា របស់យើង នៅទីនេះ យើងលើក ព្រឹត្តិការណ៍ ១៨ មីនា ឆ្នាំ ១៩៧០ មកពិនិត្យ ដើម្បីរកធាតុ គតិយុត្ត នៃ ព្រឹត្តិការណ៍។ តែជាការចាំបាច់ យើងត្រូវ ពិនិត្យ ដោយ សង្កេប នូវ ធាតុ នៃ កំណើត ចលនា សង្គមរាស្ត្រនិយម ព្រោះ វាមានទំនាក់ទំនង ដោយចំពោះ ជាមួយ ព្រឹត្តិការណ៍ ១៨ មីនា។

## ១. ធាតុ នៃកំណើត ចលនា សង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)

បើយោងតាម និក្ខេបបទ ជាផ្លូវការ ជាពិសេស របស់ ពួកសាស្ត្រាចារ្យ បារាំង បង្រៀននៅមហាវិទ្យាល័យនីតិសាស្ត្រ នៅភ្នំពេញ មួយចំនួន សរសេរ នៅក្នុងកំឡុង ឆ្នាំ ១៩៦០ ថា របប សង្គមរាស្ត្រនិយម ជារបប ពិសេសមួយ កើតឡើងពី **ប្រជ្ញាបរិច្ឆិន្ន**[7] របស់ សម្តេចសីហនុ ក្នុងគោលបំណង រក **តុល្យាការ**[8] រវាង **ប្រព័ន្ធ ដឹកនាំជាតិ**[9] ជាមួយនឹង កំពស់ នៃការចេះដឹង របស់ប្រជាពលរដ្ឋ ដែល សម្តេចសីហនុ ប្រកាសជាផ្លូវការថា ជា «របបនយោបាយ ដែលអាចឲប្រជារាស្ត្រ អាចយល់ងាយស្រួលបាន» ដូច្នេះ ពួកអ្នកការពារ របបនេះ តែងទុកកំណើត របប សង្គមរាស្ត្រនិយម ជា **បដិវត្តន៍ ស្រទន់**[10] គឺ ធ្វើកំណែទម្រង់ របបនយោបាយ ដោយមិនចាំបាច់ ប្តូរ គ្រោងសង្គមខ្មែរ។ សេចក្តីសំអាងមួយទៀត គឺ វិធី ដណ្តើមអំណាច មកកាន់កាប់ តាមលទ្ធិប្រជាធិបតេយ្យ គឺ ការបោះឆ្នោត ជាសាកល។ **សណ្ឋាន នៃគំនិត**[11]នេះ ហាក់បីមានភាពត្រឹមត្រូវណាស់ តែបើយើងលើកយក **គោលនៃគំនិត**[12] និង **វិធីប្រតិបត្តិ** មកពិនិត្យវិញ យើងឃើញថា សម្តេច សីហនុ ទ្រង់ ប្រើ ការបង្កិតបង្ខំ ជា មធ្យោបាយ ដណ្តើមអំណាចតាមវិធាន គំរាមកំហែង គ្រប់បែបយ៉ាង ដល់ គូបដិបក្ស នយោបាយ របស់ទ្រង់ ដើម្បី ធ្វើឲសម្រេច នូវគោលបំណង របស់ព្រះអង្គ គឺ **ប្រត្យាស្ថាបនា**[13] របប រាជានិយម ផ្តាច់ការ ដែលមានព្រះអង្គជាប្រមុខរដ្ឋ អស់មួយជីវិត ហើយ បន្ទប់ ព្រះបីតា របស់ ទ្រង់ ជា ព្រះមហាក្សត្រ អាយ៉ង របស់ព្រះអង្គ គ្មាន បុព្វសិទ្ធិ ជាប្រមុខរដ្ឋ ប្រទេសខ្មែរ នោះឡើយ ព្រោះ សម្តេច សីហនុ បានប្រមូល បុព្វសិទ្ធិ នេះ មកកាន់កាប់ទាំងអស់។ ការបោះឆ្នោត ថ្នាក់ជាតិ នាថ្ងៃទី ១១កញ្ញាឆ្នាំ ១៩៥៥ ដែលទុកជា មហាជោគជ័យ របស់ចលនាសង្គមរាស្ត្រនិយម ជា ផល នយោបាយ ផ្តាច់ការ របស់ សីហនុ ដែលព្រះអង្គ រៀបចំឡើង ជាមួយ វរជន មួយក្រុម តាំងពីឆ្នាំ១៩៥២មកម្លេះ។ ដើម្បី ស្ថាបនារបប សង្គមរាស្ត្រនិយម, សម្តេច សីហនុ ត្រូវចាំបាច់រំលាយ របប លទ្ធិប្រជាធិបតេយ្យសេរី ឲបាត់សូន្យ តាមកំណែទម្រង់ រដ្ឋធម្មនុញ្ញ នាថ្ងៃទី ១៤ មករា ឆ្នាំ១៩៥៦ ឲស្របនឹង

---

[6] និគ្រោះ= Réprimer។
[7] ប្រជ្ញាបរិច្ឆិន្ន=ប្រជ្ញាពិសេស ; Intelligence spécifique។
[8] តុល្យាការ= Equilibre។
[9] ប្រព័ន្ធដឹកនាំជាតិ= Système de gouvernance។
[10] បដិវត្តន៍ស្រទន់= Révolution douce។
[11] សណ្ឋាន នៃគំនិត= Forme des idées។
[12] គោល នៃគំនិត= Fond des idées។
[13] ប្រត្យាស្ថាបនា= បង្កើតឡើងវិញ ; Restaurer។

ប្រយោជន៍ព្រះអង្គ រួចទុកវា ជា ឧបករណ៍ ប្រើ ដើម្បី បង្រឹង អំណាចផ្តាច់ការ របស់ ទ្រង់ តែប៉ុណ្ណោះ[14]។

ជ័យជំនះ របស់ សម្តេច សីហនុ នៅក្នុង ឆ្នាំ ១៩៥៥ ជា ជ័យជំនះ ធ្វើឲ ជីវិតនយោបាយ សកម្មខ្មែរ **ឡើងរឹងលែងប្រែប្រួលបាន**[15] ដូចយ៉ាង **អន្តរធាន**[16] នៃគណបក្សនយោបាយ និង មានកើត **បុគ្គលិក នយោបាយ**[17] ថ្មី រស់ក្នុងលក្ខណ: ជាទាស: ព្រោះស្រវឹង នឹងស័ក្តិយស លុយកាក់។ បើយើង យកគ្រោងស្ថាប័នមកពិនិត្យ យើងឃើញថាលទ្ធិប្រជាធិបតេយ្យ សីហនុនិយម និងនយោបាយ **ប្រជាករ**[18]របស់ ទ្រង់ គឺគ្មានអ្វី ក្រៅពីវិធី សំរាប់ តែរំលាយ **ប្រព័ន្ធ តំណាង**[19] តែប៉ុណ្ណោះ។

ការប្តូររបបលទ្ធិប្រជាធិបតេយ្យសេរី មក របប ផ្តាច់ការ អាចធ្វើបានតាមតែវិធីពីរយ៉ាងគត់ ៖ បដិវត្តន៍ តាមន័យ នៃបដិវត្តន៍ កុម្មុយនិស្ត ឬ តាមផ្លូវ រដ្ឋប្រហារ។ សម្តេច សីហនុ បានជ្រើសរើស មធ្យោបាយ រដ្ឋប្រហារ។ ទ្រង់ បានធ្វើពីរដង ដែល លោក ធឿង-តុន ទុកជា រដ្ឋប្រហារ រដ្ឋធម្មនុញ្ញ នៅក្នុង និក្ខេបបទ ថ្នាក់បណ្ឌិត របស់ លោក[20]៖ ទីមួយ នៅថ្ងៃទី ១៥ មិថុនាឆ្នាំ ១៩៥២ ; ទី២ នៅថ្ងៃទី ១៣ មករា ឆ្នាំ ១៩៥៣។ ទី១ យកតំណែង នាយករដ្ឋមន្រ្តី មកកាន់កាប់ដោយខ្លួនឯង ក្នុងឋានៈខ្លួនជាព្រះមហាក្សត្រ ; ទី២ រំលាយ ខុសច្បាប់រដ្ឋធម្មនុញ្ញ រដ្ឋសភា។

ដូច្នេះ ការដណ្តើម អំណាច មកកាន់កាប់ របស់ សម្តេច សីហនុ ជា រដ្ឋប្រហារ ប្រើ រាជសក្តិ[21] ជា **គាហបញ្ញា**[22] យកអំណាចគ្រប់បែបយ៉ាងមកធ្វើជា កម្មសិទ្ធិ របស់ខ្លួន។ ការដណ្តើម អំណាចនេះ អាចចាត់ទុកវា ជា វិធី គ្មាន **នីត្យានុកូល**[23] គ្មាន **ធម្មានុរូប**[24]។ នីត្យានុកូល ព្រោះ វាមិនស្របនឹង រដ្ឋធម្មនុញ្ញ ; ធម្មានុរូប ព្រោះ ក្នុង ឋានៈជា ព្រះមហាក្សត្រ អាស្រ័យ រដ្ឋធម្មនុញ្ញ គ្មានសិទ្ធិ ប្រើ រាជសក្តិ ដែលគ្រាន់តែជា **អំណាច ជានិមិត្តរូប**[25] ដើម្បី យកអំណាច និតិបញ្ញាតនិង និតិប្រតិបត្តិ មកកាន់កាប់។ ទង្វើនេះឯង ដែលជាការបញ្ជាក់ នូវលក្ខណ: រដ្ឋប្រហារ របស់ សីហនុ ដែល ទ្រង់ យកវាមក **ប្រើ ជារបៀប និង ជាយន្ត**[26] ដើម្បី ស្វែងរកជោគជ័យ នៃ **ចំណង់ នូវអំណាច**[27] របស់ ទ្រង់ តែប៉ុណ្ណោះ។ ដូច្នេះ អវត្តមាន ជីវិត នយោបាយ នៅស្រុខ្មែរ ចាប់មានតាំង ពីឆ្នាំ ១៩៥៥ រហូត មកដល់ ឆ្នាំ ១៩៦៥ ជា ឆន្ទៈ របស់ សីហនុ សំរាប់បំផ្លាញលិទ្ធិប្រជាធិបតេយ្យ។ ក្នុងឆ្នាំ ១៩៦៥ ព្រះអង្គ ប្តូរ របៀប ចុះឈ្មោះ បេក្ខភាព តំណាងរាស្ត្រ ដែលខុសផ្លែកពីមុនៗ គឺថា ចលនា សង្គមរាស្ត្រនិយម លែងជ្រើសរើស បេក្ខជន តំណាងរស្ត្រ ជាមុន រួចដាក់បេក្ខជនទាំងនេះ ឲប្រជាពលរដ្ឋ ជ្រើសយក បុគ្គលណាមួយ ដែលខ្លួនពេញចិត្ត។ ការប្តូរនេះជា

14 សុំអាន ការសាកល្បងសិក្សា របស់ខ្ញុំ មានចំណងជើងថា «សតវត្ស អធម៌»។
15 ឡើងរឹង លែងប្រែប្រួល= Scléroser។
16 អន្តរធាន= បាត់ ; Disparaître។
17 បុគ្គលិកនយោបាយ= Personnel politique។
18 ប្រជាករ= Masse populaire។
19 ប្រព័ន្ធតំណាង= ប្រព័ន្ធដឹកនាំ ដែលមានអ្នកតំណាងប្រជាពលរដ្ឋ ; Système représentatif។
20 La crise cambodgienne – Thèse pour le doctorat (1954) : Faculté de droit de Paris។
21 រាជសក្តិ= អំណាច ស្តេច ; Pouvoir royal។
22 គាហបញ្ញា= សិទ្ធិទទួលយកអ្វីមួយ ដែលគ្មានការអនុញ្ញាតពីច្បាប់. Saisine។
23 នីត្យានុកូល=ពេញលក្ខណ:ច្បាប់ ; Légal។ លក្ខណ: ដែលស្របនឹងច្បាប់= Légalité។
24 ធម្មានុរូប= ត្រូវច្បាប់ ; Légitime។ លក្ខណ: ដែលមានសិទ្ធិជាមូលដ្ឋាន= Légitimité។
25 អំណាចជានិមិត្តរូប= Pouvoir symbolique។
26 ប្រើ ជារបៀប និង ជាយន្ត=Utiliser méthodiquement et mécaniquement។
27 ចំណង់នូវអំណាច= Désir du pouvoir។

សញ្ញាបើក យុគថ្មី នៃ ជីវិតនយោបាយខ្មែរ ដែលអាចចាត់ទុកជា **សេរីការ**[28] មានកំរិតមួយ របស់ សម្តេច សីហនុ តែវាមាន ផលប៉ះពាល់ ខ្លាំងណាស់ ដល់ ជីវិតនយោបាយខ្មែរ ព្រោះ រដ្ឋសភា កើតពី សេរីការនេះ លែងមានលក្ខណ: ជា រដ្ឋសភា គោរពផ្កាប់មុខ **កបិចិត្ត**[29] របស់ សម្តេច សីហនុ ហើយបន្ទាប់មក ក្លាយជារដ្ឋសភាព ហ៊ានជំទាស់ចេញមុខ បន្តិម្តងៗ ប្រឆាំង និងនយោបាយ សម្តេច សីហនុ។

## ២. ធាតុ នៃកំណើត របប សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

យើងអាចចាត់ទុក ព្រឹត្តិការណ៍ ១៨មិនា ជា **ប្រតិកម្ម** ប្រឆាំងនឹង អាកប្បកិរិយា នយោបាយ **អវិចារណ៍**[30] របស់ សម្តេច សីហនុ ក្នុង វិបត្តិ សំខាន់ ដែលជាតិ ជួបប្រទះ។ នៅចំពោះមុខ **អវិចារណ៍ភាព** នេះ លោក លន់-នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថ សិរិមត: មានជម្រើស ពីរយ៉ាង ៖ ប្រើកម្លាំង ឬ ប្រើ ច្បាប់។

លោក ឧត្តមសេនីយ លន់-នល់ ដែលជាអតីត: ចៅក្រម តែងតែមាន **ទំលាប់ជាយត្ត**[31] យកច្បាប់ជាមូលដ្ឋាន រកដំណោះស្រាយ នៃបញ្ហា។ តែនៅចំពោះមុខ ករណី សីហនុ, វាមាន ការច្រឡំដ៏សំខាន់មួយ ដែលនាំ អ្នកខ្លះ មានមតិថា ការទំលាក់ សម្តេច សីហនុ ពីដំណែង ប្រមុខរដ្ឋ អស់មួយជីវិត ជា រដ្ឋប្រហារ ព្រោះ លក្ខណ: «អស់មួយជីវិត» ជា «ពិសិដ្ឋ» ឥតអាចនរណា ប៉ះពាល់ បាននោះឡើយ តែអ្នកទាំងនោះ ភ្លេចគិតថា ដំណែង របស់ សម្តេច សីហនុ មាន **សភា**[32] ជាអ្នកតែងតាំង ដែលមានចារនៅក្នុង រដ្ឋធម្មនុញ្ញ កែប្រែ ក្នុង ឆ្នាំ ១៩៦០ ដូច្នេះ អ្វី ដែលកើតឡើងពីច្បាប់ គេអាចយកច្បាប់ ទៅ រំលាយបាន៖ សភា ជា អ្នកតែងតាំង ដូច្នេះ សភានេះ ក៏អាច លុប ការតែងតាំង នេះ បានដែរ។ ដូច្នេះសភា មាន ធម្មានុរូប ពេញលេញ ក្នុងការហូតងារ សម្តេច សីហនុ ពីដំណែង «ប្រមុខរដ្ឋ»។ ទង្វើនេះ មានមូលដ្ឋានច្បាប់ជា គ្រឹះ ជា ទង្វើ ស្របច្បាប់ ដែលគេ ពុំអាចចាត់ទុកវា ជារដ្ឋប្រហារ បាននោះឡើយ។

មុននឹង ធ្វើវិភាគ ជាគតិយុត្ត អំពីការហូតងារ សម្តេច សីហនុ ពីសំណាក់ សភា  យើងគួរ លើកយក កត្តានយោបាយ ជាច្រើន មកពិនិត្យ ជាមុនសិន ដើម្បី ឲស្រួលយល់ អំពី ដំណើរ នៃកំណើត ព្រឹត្តិការណ៍ ១៨មីនា។

### កត្តា ក្នុង ប្រទេស

ទ្រឹស្តី នយោបាយ របស់ ចលនា សង្គមរាស្ត្រនិយម ឬ សីហនុនិយម ទាមទារថា ជា «**សង្គមនិយម ពុទ្ធសាសនា**» ទទួល បរាជ័យ ជាក់ច្បាស់ ដែលតម្រូវចាំបាច់ ឲសម្តេច សីហនុលើកយកវា មកពិនិត្យ ឡើងវិញជាថ្មី នៅក្នុងឆ្នាំ ១៩៦៩ ព្រោះវាជួបប្រទះនឹង វិបត្តិ គ្រប់វិស័យ បង្កើតជាផលវិបាក ដល់ ប្រជាជាតិ។ ការពិនិត្យ ឡើងវិញ នេះ ជាកំណើត នៃ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែល សម្តេច សីហនុ ស្នើឲ លោក ឧត្តមសេនីយ លន់-នល់ ដឹកនាំ ដើម្បីប្តូរទិសដៅ

28 សេរីការ= Libération។
29 កបិចិត្ត= ចិត្តរបិុលរប៉ូច ; Caprice។
30 អវិចារណ៍= មិនមានហេតុផល, ផ្ទុយនឹងវិចារណញ្ញាណ ; Irrationnel។
31 ទំលាប់ជាយត្ត= Habitude mécanique។
32 សភា= រដ្ឋសភា និង ក្រុមព្រឹក្សាព្រះរាជអាណាចក្រ។

នយោបាយថ្មី។ រដ្ឋាភិបាល លោក លន់-នល់ ត្រូវបាន រដ្ឋសភា បោះឆ្នោត ប្រគល់សេចក្តីទុកចិត្តដើម្បី រកដំណោះស្រាយ វិបត្តិជាតិ។

**១. វិបត្តិ សេដ្ឋកិច្ច**

បើមើលតាម ប្រវត្តិសាស្ត្រ បន្ទាប់ពី ស្រុកខ្មែរ ទទួលបាន ឯករាជ្យ ឃើញថា នយោបាយសេដ្ឋកិច្ច បែងចែកជា សម័យពីរៈ ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៦៣ គឺជា សម័យ សេដ្ឋកិច្ច សេរី ដែលជា មរតក នៃសេដ្ឋកិច្ច អាណានិគមបារាំង និង ជំនួយ បរទេស ជាពិសេសជំនួយ របស់ សហរដ្ឋអាមេរិ។ បន្ទាប់ពី ឆ្នាំ ១៩៦៣ មក សម្តេច សីហនុ ប្តូរ នយោបាយសេដ្ឋកិច្ច យក របៀបសង្គមនិយម មកអនុវត្តិ វិញ តែនយោបាយថ្មីនេះ បានប្រទះនឹង បរាជ័យ ដូចរៀបរាប់ខាងក្រោមនេះ។

**នៅក្នុង វិស័យ កសិកម្ម** (90% ប្រជាជនខ្មែរ ជា កសិករ) អ្នកឯកទេស សេដ្ឋកិច្ច កត់សំគាល់ថា មូលហេតុ នៃបរាជ័យ មានច្រើនយ៉ាងៈ

- អវត្តមាន នៃ វិនិយោគ ដែលជា មូលដ្ឋាន ចាំបាច់ សំរាប់ អភិវឌ្ឍន៍ កសិកម្ម ប្រពៃណី ដូចយ៉ាង ការបញ្ចូលទឹក ជាអាថ៌ ;

- បរាជ័យ ក្នុង វិស័យ សហករណ៍ ;

- បរាជ័យ ផែនការណ៍ ប្រឆាំងនឹង **ព្រីទ្ធិកម្ម**[33] ;

- ការបំផ្លាញ ធនធាន ធម្មជាតិ ;

- ការជិះជាន់ បោយយកប្រយោជន៍ លើ ប្រជាកសិករ ពីសំណាក់ អាជ្ញាធរ និង ឈ្មួញទុច្ចរិត។

**នៅក្នុង វិស័យ ឧស្សាហកម្ម វប្បកិច្ច**[34] ដូចយ៉ាង ដាំ កៅស៊ូ, កាហ្វេ, តែ និង ដើមក្រចៅ ឃើញមាន ការចំរើន ដែលអាចទុកជា ជោគជ័យ តែ ជោគជ័យ នេះ គ្មាន **ប្រតិឃាត**[35] ដោយចំពោះដល់ ជីវភាព អ្នកស្រែចំការ នោះទេ។

**នៅក្នុង វិស័យ ឧស្សាហកម្ម** ដោយខ្វះ មូលធនជាតិ ចាប់ពីឆ្នាំ ១៩៦០ សម្តេច សីហនុ យកជំនួយ ប្រទេសចិន ដើម្បី បង្កើត សហគ្រាស រដ្ឋ និង ក្រុមហ៊ុន **សេដ្ឋកិច្ច ចំរុះ**[36] តែ វិធានការនេះ មិនមាន ជោគជ័យ នោះឡើយ។ បរាជ័យ មាន មូលហេតុ ពីរយ៉ាងៈ អវត្តមាន នៃ **សនិទានភាព**[37] នៃ ការបង្កើត រោងចក្រ និង ទីកន្លែង សំរាប់ សង់ រោងចក្រ ; ការចាត់ការ មិនល្អ នៃក្រុមអ្នកដឹងនាំ និង ចរិត ទុច្ចរិត របស់ ពួក នេះ។

**នៅក្នុង វិស័យ ពាណិជ្ជកម្ម និង ធនាគារ** មានលក្ខណៈ ជា **ឯកធិភាព**[38] របស់ រដ្ឋ។ ផ្នែកនេះបានក្លាយជា កម្មសិទ្ធិ របស់ អ្នកបញ្ចោររកប្រយោជន៍ រស់នៅជុំវិញ សម្តេច សីហនុ ដែលជា ពួក

33 ព្រីទ្ធិកម្ម= ការចងការប្រាក់ ដោយយកចុងច្រើម ; Usure។
34 ឧស្សាហកម្ម វប្បកិច្ច= ឧស្សាហកម្ម ដាំដំណាំ ;Cultures industrielles។
35 ប្រតិឃាត= ផល, ទុង្គកទង្គើ ; Répercussion។
36 សេដ្ឋកិច្ចចំរុះ= Economie mixte។ មូលធនរដ្ឋ រួមជាមួយ មូលធនឯកជន។
37 សនិទានភាព= ភាពសមហេតុផល ; Rationalité
38 ឯកធិភាព= ផ្តាច់មុខ ; Monopole។

ទុច្ចរិត បំផ្លាញប្រជាជាតិខ្មែរ។ ឧទាហរណ៍ មានច្រើន ដូចយ៉ាង ជំនួញ ការបង្ហូរទឹក ចូលទៅក្នុង រោងចក្រ បិត ស្រាបៀរ នៅក្រុងសីហនុ និង ការនាំចូល ខ្ទឹមស ពីប្រទេសចិន ; ក្រុមអ្នកដឹង នាំ ហាងរដ្ឋ និង រោងចក្រ ធ្វើទឹកដោះគោខាប់ សុទ្ធ ជា គ្រួសារ សាច់ថ្លៃ និង អាមាត្រ របស់ សម្ដេច សីហនុ ស្ទើរ តែទាំងអស់។

ចាប់តាំង ពី ឆ្នាំ ១៩៦៣មក, សម្ដេច សីហនុ ប្តូរពី នយោបាយ សេដ្ឋកិច្ច សេរី មកជា សេដ្ឋកិច្ច មានផែនការណ៍[39] ទាត់ចោល ជំនួយ អាមេរិកាំង រួចយក ជំនួយ ចិន និង លោក កម្មុយនិស្ត ជា**ការទូទាត់**[40] តែដូចបានបរិយាយ ខាងលើនេះ វិធានការ នេះ វា គ្មាន សនិទានភាព គ្មាន **ជាប់ស្និទ្ធ**[41] ហើយ អ្នកចាត់ការ ច្រើនជា **ប្រទុសជន**[42]។ ការបត់ទៅខាងឆ្វេង នេះ ទុកជា **កបិចិត្ត**[43]របស់ សីហនុ ញោរ តាម ការប្រចុមប្រចែង របស់ លោក ជូ-អេងឡាយ, រដ្ឋមន្ត្រីទី១ នៃ ប្រទេសចិនកុម្មុយនិស្ត ដែលជាអន្ទាក់ ទាក់ សីហនុ ឲចូលក្នុង ទ្រុង លោក កុម្មុយនិស្ត។

## ២. វិបត្តិ សីលធម៌

វិបត្តិ សីលធម៌ ជា វិបត្តិទូទៅ តែមាន សណ្ឋាន ផ្លែកៗគ្នា ទៅតាម មជ្ឈដ្ឋានៈ

មជ្ឈដ្ឋាន ប្រជាកសិករ ដែលជា ពួកអ្នកក្រ ទទួល ការជិះជាន់ ពីសំណាក់ ពួកអ្នករាជការ គ្រប់ក្រសួង ថែមទាំង អង្គការ សហករណ៍ គាបសង្កត់ ទៅលើ ប្រជាកសិករ គ្មានខ្លាច អប្បយស តាម ការហូត ពន្ធអាករ ហួសហេតុ ហើយ លួច រដ្ឋ ជាក្រុមចោរ ដើម្បី ធ្វើជា អ្នកមាន។

ទាំង អ្នករាជការជាន់ខ្ពស់ និង បញ្ញាវន្ត ជាច្រើន រួមរស់ នៅក្នុង ប្រពន្ធ ពុករលួយ បានទទួលផល ពីមុខដំណែងរបស់ខ្លួន នាំគ្នា យកលុយ បានមកពីអំពើទុច្ចរិត ទៅសង់ ភូមិគ្រឹះប្រណិត សំរាប់ជួលឲ ពួកអ្នកឯកទេស បរទេស ដែលមានតម្លៃឈ្នួល ស្មើនឹង តម្លៃមាសជួនកាល យកលុយ នោះ ទៅដូរជា រូបិយប័ណ្ណ យកទៅដាក់ក្នុង ធានាគារ នៅឯបរទេស។ គួរកត់សំគាល់ថា អ្នករាជការ និង បញ្ញាវន្ត ស្អាតស្អំ ត្រូវមិត្តភ័ក្តិ ឬ ញាតិ ខ្លួន ទុកជាមនុស្សល្ងង់គ្មានប្រាជ្ញា ដើម្បី រកលុយ ធ្វើជា អ្នកមាន ដូច ពួកប្រទុសជន។

ការរត់ពន្ធ អង្ករ លក់ឲពួកវៀតកុង បានតម្លៃថ្លៃ ពីសំណាក់រាជវង្សគ្រប់វង់ ក្លាយជាកីឡាជាតិ ដែលនាំឲអង្ករ ឡើងថ្លៃ នាំឲ ពួកអ្នកក្រ និង ពួកអ្នកមធ្យម ជួបនឹង វិបត្តិ ជីវភាព រស់នៅ។

ការបង្កើត រោងល្បែង (កាស៊ីណូ) នៅ រាជធានី ភ្នំពេញ និង នៅ ទីក្រុង ព្រះសីហនុ ជាការគំរាមកំហែង ដល់ សីលធម៌ ពុទ្ធសាសនា និង ជាតិ ពីសំណាក់ របបមួយ ដែលប្រកាសខ្លួនថា ជា សង្គមរាស្ត្រនិយម ពុទ្ធសាសនា។

អង្គការ កាកបាទ ក្រហម ដែលដឹកនាំ ដោយ អ្នកម្នាង មូនិច ក្លាយជា ឧបករណ៍ ឯកជន សំរាប់ សង្កត់សង្កិតប្រជារាស្ត្រ ដោយ បង្ខំ ឲចុះឈ្មោះ ចូលជា សមាជិកដាច់ខាត បង់វិភាគទាន សំរាប់ បំរើ អង្គការ តែប៉ុណ្ណោះ។

---

[39] សេដ្ឋកិច្ច មានគម្រោងការណ៍= រដ្ឋ ជាអ្នក ធ្វើគម្រោងការណ៍ សេដ្ឋកិច្ច ; Economie planifiée។
[40] ការទូទាត់= ជាសំណង នូវការបាត់បង់ ; Compensateur។
[41] ជាប់ស្និទ្ធ= ជាប់គ្នា, ទាក់ទងគ្នា ; Cohérent។
[42] ប្រទុសជន= Personne corrompue et perverses។
[43] កបិចិត្ត= ចិត្តសាវ៉ា ; Caprice។

ជាទីបញ្ចប់ ចាប់ពីឆ្នាំ ១៩៦៦ សម្ដេច សីហនុ ងប់ ក្នុងឲអស់សំណើច ក្នុង សកម្មភាព នៃ ភាពយន្ត ដោយប្រើ មធ្យោបាយ រដ្ឋ ហើយ លែងសូវគិត អំពី កិច្ចការជាតិ។ ដែលនាំឲ ខ្មែរ អ្នក ជា នាំគ្នា និយាយ ខ្សឹបៗគ្នា ជាការចំអកឡកឡឺយ ថា សសរគោល នៃ ប្រព័ន្ធ សីហនុ មានបី គឺ ៖ កាកបាទ ក្រហម, កាស៊ីណូ និង ភាពយន្ត។ ការចំអកឡកឡើយនេះ មានលាក់ នូវ ការអស់ សង្ឃឹម និង អាប្បយស នៃ ប្រជាពលរដ្ឋខ្មែរ ដែលមាន សម្ដេច សីហនុ ជាទួឯក បំផ្លាញជាតិ។

## ៣. វិបត្តិ ស្ថាប័ន

គ្រប់ ស្ថាប័ន សម័យ ដែលទទួល ពី អាណាចរ អាណានិគមបារាំង ធ្លាក់ ទ្រុឌទ្រោម បន្តិចម្ដងៗ នៅក្នុងប្រព័ន្ធ ចលនា សង្គមរាស្ត្រនិយម។ ការកែប្រែ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ក្នុងឆ្នាំ១៩៥៦ ដើម្បី តម្រូវនឹង ប្រយោជន៍ ចលនា សង្គមរាស្ត្រនិយម ឬ ប្រយោជន៍ របស់ សីហនុ ជាអំពើ បំផ្លាញ លទ្ធិប្រជាធិបតេយ្យ។

**លើឋាន**[44] **រដ្ឋបាល**, ម៉ាស៊ីន ចាប់ផ្ដើម ខូច បន្តិចម្ដងៗ ព្រោះមកអំពី គុណភាព មិនល្អ៖ យក អំណាចបំពាន មកធ្វើជា ការដឹកនាំ ; យក ការ ជិះជាន់ ប្រជារាស្ត្រ ជា ការឆ្លៀត រកកម្រៃ ដើម្បី ធ្វើជា អ្នកមាន។

ការតែងតាំង បុគ្គលិក យោធា ជា អភិបាលខេត្រ និង **អនុខេត្រ**[45] នាំ បង្កើត **ព្យាកុលភាព**[46] រវាង ក្រសួងមហាផ្ទៃ និង ក្រសួង ការពារជាតិ។ ការតែងតាំង ព្រះរាជប្រតិភូ សំរាប់ ដឹកនាំ ខេត្រ នាំឲក្រសួងមហាផ្ទៃ បាត់ អំណាចក្រសួង ព្រោះ ព្រះរាជប្រតិភូ ទទួលខុសត្រូវ នៅតែចំពោះមុខ ព្រះប្រមុខរដ្ឋ តែប៉ុណ្ណោះ។

**លើឋាន ហិរញ្ញវត្ថុ**, អវត្តមាន នៃថវិការជាតិ ពិតប្រាកដ លើកលែង តែ ថវិការ សំរាប់ សកម្មភាពការងារ ជា ច្រើន ដែល ខុទ្ទកាល័យ ព្រះប្រមុខរដ្ឋ យក ទៅកាន់កាប់ផ្ទាល់ ដូចយ៉ាង ចំណាយ ក្នុងកិច្ចការ សង្គមកិច្ច និង សាធារណការ។ ថវិការ នេះ បានមក ពី អំណោយឯកជន **សយម្ភូត**[47] ដល់ ព្រះប្រមុខរដ្ឋ ផ្ទាល់, ប្រាក់ជំនួយ ពី រដ្ឋ, សហគ្រាស រដ្ឋ និង វិភាគទាន ប្រធាននាយក ដែលជាតម្លៃ កៅអី។ ប្រព័ន្ធ ហិរញ្ញវត្ថុ បែបនេះ ជា ប្រភពនៃអំពើ ពុករលួយ ដែលនាំឲកើត រោគពិស ដល់ ប្រជាជាតិ។

យើងអាចធ្វើសង្ខេបបាន អំពី ការវិវត្តន៍ នៃ ស្ថាប័ន ជាតិ ជា បួន ភិនភាគ៖ ទី១ របប លទ្ធិប្រជាធិបតេយ្យសេរី ; ទី២ របប ចលនាសង្គមរាស្ត្រនិយម ; ទី៣ **ការយោល**[48] រវាង ប្រព័ន្ធ អាស្រ័យសភា នឹង ការទទួលខុសត្រូវ របស់ រាជរដ្ឋាភិបាល ដែលមាន **ព្រះប្រមុខរដ្ឋនិយម**[49] ជា ម្ចាស់អំណាច ; ទី៤ របប លទ្ធិប្រជាធិបតេយ្យ ដោយចំពោះ ឈរ លើ ស្ថាប័នជាតិពីរ ៖ សមាជ ជាតិ និង ប្រជាមតិ។ តែយើងដឹងថា សម្ដេច សីហនុ ទ្រង់ យក អំណាចរដ្ឋ ធ្វើជា

44 លើឋាន=Sur le plan។
45 អនុខេត្រ បង្កើតឡើងក្នុងគោលបំណង ប្រឆាំងនឹង វិទ្ធង្សនា កុម្មុយនិស្ត។
46 ព្យាកុលភាព= ភាពច្របូកច្របល់ ; Confusion។
47 សយម្ភូត= ដែលធ្វើទៅដោយឯងៗ ; Spontané។
48 ការយោល= Oscillation។
49 ព្រះប្រមុខរដ្ឋនិយម ឬ ប្រធានាធិបតីនិយម= Présidentialisme។

ឧបករណ៍ នយោបាយ របស់ ព្រះអង្គ ប្រើ សំរាប់ ពង្រឹង អំណាចផ្ដាច់ការ ដែលនាំ ឲ ការវិវត្តន៍ ស្ថាប័ន ទៅរកអំណាចផ្ដាច់ការ។

## ៤. វិបត្តិ នយោបាយ

គោល នយោបាយ របស់ សម្ដេច សីហនុ តាំងពីឆ្នាំ ១៩៥៤ គឺ «ការរួបរួមជាតិ» ដែលទុកជា ធាតុដើម នៃ ចលនា សង្គមរាស្ត្រនិយមៈ រួបរួម ខ្មែរ អ្នកជាតិនិយម ក្រៅ គ្រោង គណបក្សនយោបាយ។ គំនិត នេះ ចាប់មាន ទ្រង់ទ្រាយ ឡើង ពី ឆ្នាំ ១៩៥២ ក្នុងគោលការ ពីរយ៉ាងៈ ទី ១ គឺ បំបាត់ ជាបន្ទាន់ គណបក្ស នយោបាយ ជា ពិសេស គណបក្ស ប្រជាធិបតេយ្យ ដែលជា គណបក្ស ភាគច្រើន នៅក្នុង រដ្ឋសភា តាំងពីឆ្នាំ ១៩៤៧ ; ទី២ ជា គោលដៅ មាន កាលកំណត់ វែង គឺ រារាំង ទំនាស់ ហឹង្សា រវាង ពួក អ្នកឆ្វេងមិយម មាន និន្នាការ ម៉ាវ្សនិយម ដែលជា ពួក អតីតៈ ខ្មែរ វៀតមិញជាមួយនឹង អ្នកស្តាំនិយម មាននិន្នាការ ជាតិនិយម។

ក្នុងរយៈ ឆ្នាំ ១៩៥៤ ដល់ ១៩៦៧ គោលដៅនេះ មាន ប្រសិទ្ធិភាព ពិត សំរាប់ សម្ដេចសីហនុ ; ទ្រង់ ឈរ នៅទីកណ្ដាល នៃ ចលនា ទាំងពីរ ប្រតិបត្ត នយោបាយ **ទម្ងន់ទូទាត់**[50] អាចឲទ្រង់ កំចាត់ចោលបាន វរជន សម-សារី ដែលជា អ្នកស្តាំនិយម និយម អាមេរិកាំង ហើយបញ្ចូល វរជន ឆ្វេងនិយម ដូចយ៉ាង លោក ហ៊ូ-យន់ និង ខៀវ-សំផន ក្នុង រាជរដ្ឋាភិបាល ដើម្បីឲមក ចាត់ចែង នយោបាយ សេដ្ឋកិច្ច តាមទ្រឹស្ដី របស់ខ្លួន។ ឯចំណែក គណបក្សប្រជាជន ដែលជា គណបក្សកុម្មុយនិស្ត និយមយួនកុម្មុយនិស្ត បាត់ ឥទ្ធិពល របស់ខ្លួន ក្នុង សង្គម និង លើឆាក នយោបាយខ្មែរ។

ព្រឹត្តិការណ៍ សំខាន់មួយ មានកើតឡើង គឺ ការសម្រេចចិត្ត របស់ សម្ដេច សីហនុ បើកសេរីភាព ឲសមាជិក ចលនា សង្គមរាស្ត្រនិយម មានសេរីភាព អាចឈរឈ្មោះ ជាបេក្ខជន តំណាងរាស្ត្រ ដោយគ្មានការជ្រើសរើស ជាមុន ពីចលនា។ សេរីការ នៃនយោបាយ ក្នុង ចលនា ក្នុងឆ្នាំ១៩៦៥ នេះ មានគោលដៅខ្មៅ ច្បាស់លាស់ គឺ ទម្លាក់ចោល វរជន ឆ្វេងនិយម ដែលមាន ប្រជាប្រិយភាព ពី តំណាងរាស្ត្រ តាម **ប្រជាការបោះឆ្នោត**[51] ដូចជា លោក ខៀវ-សំផន, ហ៊ូ-យន់និង ហុយ-នឹម តែលទ្ធផល បែរផ្ទុយពីការចង់បានទៅវិញ គឺ វរជន ទាំងបីរូបនេះ បានទទួលជ័យជំនះ ជាប់ឆ្នោតជាតំណាងរាស្ត្រឡើងវិញ។ មិនតែប៉ុណ្ណោះ ក្នុង រដ្ឋសភា ថ្មី នេះ ពួក អ្នកស្តាំនិយម និងពួក អ្នកមិនមែន ជា សីហនុនិយម ផ្កាប់មុខ ឈ្នះឆ្នោត លើសលុប។ ស្ថានការណ៍ ថ្មីនេះបង្ខំ ឲ សម្ដេចសីហនុ តែងតាំង លោក ឧត្តមសេនីយ លន់-នល់ ជា នាយករដ្ឋមន្ត្រី តែ បន្តិចទៅ ព្រះអង្គ ក៏បង្កើត **បររដ្ឋាភិបាល**[52] ដែលមានសមាជិក ច្រើន ជា អ្នកឆ្វេងនិយម និង អ្នកសីហនុនិយមគ្មានល័ក្ខខ័ណ្ឌ សំរាប់ឃ្លាំមើល សកម្មភាព រដ្ឋាភិបាល លោក លន់-នល់។ យុទ្ធសាស្ត្រ នយោបាយថ្មី របស់ សម្ដេច សីហនុ នេះ ជា យុទ្ធសាស្ត្រ ភ្លាត់ របស់ ព្រះអង្គ ព្រោះ នាំ ឲ ពួកអ្នកឆ្វេងនិយម ចាប់ផ្ដើម បង្កើត ចលនា តស៊ូ តាម កម្លាំង អាវុធ នាំឲ លោក ខៀវ-សំផន, ហ៊ូ-យន់និង ហុយ-នឹម រត់ចូលព្រៃ ចុះចូលក្នុង ចលនា តស៊ូ កុម្មុយនិស្ត ហើយ បួនឆ្នាំ ក្រោយមក រដ្ឋសភា នេះឯង បានបោះឆ្នោត ទំលាក់ ព្រះអង្គ ពីដំណែង ប្រមុខរដ្ឋ អស់មួយ

[50] ទម្ងន់ទូទាត់= Contrepoids។
[51] ប្រជាការបោះឆ្នោត= Suffrage populaire។
[52] បរ រដ្ឋាភិបាល= រដ្ឋាភិបាលមួយទៀត ; Contre-gouvernement។

ជីវិត។ តែ **សន្ធ្យាកាល**[53] នៃ សីហនុនិយម ចាប់ផ្ដើមតាំង ពីឆ្នាំ ១៩៦៧ មកម្លេះ ដោយសារ សីហនុ ខ្លួនឯង ធ្វើនយោបាយ ប្រាសចាក សីលធម៌។

## កត្ដា ក្រៅ ប្រទេស

តាំង ពីឆ្នាំ ១៩៥៤ នយោបាយ ក្រៅប្រទេស របស់ សម្ដេច សីហនុ គឺ ឈរលើ «អព្យាក្រឹតភាព» ទោះបី មានសម្ពាត តាមផ្លូវទូត ពីសំណាក់ សហរដ្ឋអាមេរិក ចង់ឲ្យ ប្រទេសខ្មែរ ចូលជាសមាជិក **អង្គការ សន្ធិសញ្ញា អាស៊ី បែក អគ្នេយ៍**[54] ក៏ដោយ។ ពិតប្រាកដណាស់ ថាមានគម្រងការណ៍អាក្រក់ ចង់សម្លាប់ ព្រះអង្គ ពីសំណាក់ វៀតណាមខាងត្បូង រួមជាមួយ C.I.A. ដូចយ៉ាង គម្រងការណ៍ ធ្វើរដ្ឋប្រហារ របស់ លោក ដាប-ឈួន និង គម្រងការណ៍ ធ្វើ **អនត្ថការ**[55] ដាក់គ្រាប់បែកនៅក្នុង ព្រះបរមរាជវាំង របស់ វៀតណាមខាងត្បូង តែ ព្រឹត្តិការណ៍ ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០ កើតឡើងមក ពីវិបត្តិនយោបាយ ក្នុង ប្រទេស គ្មានមាន អន្តរាគមន៍ អ្វីឡើយ ពីសំណាក់ C.I.A. ដូចដែរ សម្ដេច សីហនុ ចោទប្រកាន់ នោះឡើយ ព្រោះថា សហរដ្ឋអាមេរិក ប្ដូរនយោបាយ នៅប្រទេស វៀតណាម យក ដំណោះស្រាយ នយោបាយ មក ជំនួស នយោបាយសង្គ្រាម ហើយ ចាប់ផ្ដើ ធ្វើការទំនាក់ទំនង ជាថ្មី ជាមួយ កម្ពុជា។ សហរដ្ឋ អាមេរិក មានបំណងតែមួយគត់ ក្នុងនយោបាយដកទ័ព ចេញពី វៀតណាម គឺ សុំឲ្យ ប្រទេសខ្មែរ ប្រកាន់ នយោបាយអព្យាក្រិត ពិតប្រាកដ តែប៉ុណ្ណោះ ដោយយក ប្រទេសចិន ជាអ្នកធានា នូវអព្យាក្រិតភាពខ្មែរ។ ដូច្នេះ សហរដ្ឋអាមេរិកគ្មានប្រយោជន៍អ្វី ចង់ដូរ របបនយោបាយ ឬ អ្នកដឹងនាំជាតិខ្មែរ នោះឡើយ។ ចំពោះ អាមេរិកាំង សីហនុ និង លន់-នល់ គឺ ឆ្នា មានពណ៌ ខុសគ្នាតែប៉ុណ្ណោះ។

តែយើងដឹងថា អព្យាក្រឹតភាពខ្មែរ គឺ សម្ដេច សីហនុ ជា អ្នកបំពានដោយខ្លួនឯង ដោយអនុញ្ញាតឲកងទ័ព វៀតកុង មកតាំងទី ក្នុងទឹកដីខ្មែរ មិនតែប៉ុណ្ណោះ អនុញ្ញាត ឲប្រើទឹកដីខ្មែរ សំរាប់ដឹងជញ្ជូន អាវុធយោធា និង ស្បៀង ផ្ដល់ឲ រណសិរ្ស វៀតកុង ធ្វើសង្គ្រាម នៅក្នុងប្រទេស វៀតណាមខាងត្បូង។ វត្តមាន កងទ័ពយួនកុម្មុយនិស្ត មានចំនួន ៦៥.000 នាក់ នៅស្រុកខ្មែរនេះឯង ដែលជា មូលហេតុ នៃការទំលាក់គ្រាប់បែក អាមេរិកាំង នៅ ភូមិ ចន្ទ្រា ក្នុង ឆ្នាំ ១៩៦៦និង ភូមិ ដាក់ដាំ ក្នុង ឆ្នាំ ១៩៦៩ ដែលជាទីតាំង ជុំរុំ ទ័ព វៀតកុង ដែលនាំឲខ្មែរ ស្លាប់ជាច្រើននាក់។ គេអាចសួរជាសំណួរ បានថា តើទង្វើនេះ ជា ការរំលោភ ទឹកដីខ្មែរ ឬ ជាសិទ្ធិ ដេញតាមសត្រូវ ដែលរត់មកពួន នៅប្រទេសខ្មែរ ?

សម្ដេច សីហនុ ចាប់ផ្ដើម មាន ការបារម្ភ អំពី ការជ្រៀតជ្រែក ចិនកុម្មុយនិស្ត ក្នុងនយោបាយខ្មែរ ចាប់ពីឆ្នាំ ១៩៦៧ និង វត្តមាន ទ័ព យួនកុម្មុយនិស្ត នៅកម្ពុជា។ ការបារម្ភ នេះ ដែលជាមូលហេតុ នៃការ រកទំនាក់ទំនង ជាថ្មី ជាមួយ សហរដ្ឋអាមេរិក តែ នៅក្នុងឆ្នាំ ដដែលនេះ ទ្រង់ នៅតែបន្តនយោបាយ ជួយ និង លាក់ ទ័ពវៀតកុង នៅក្នុងស្រុខ្មែរ ដូចយ៉ាងទ្រង់យាង ទៅ ធ្វើបុណ្យសព លោក ហូ-ជីមិញ នៅទីក្រុងហាណូយ ដែលនៅក្នុងពេលនោះ មានតែព្រះអង្គមួយគត់ ជា ប្រមុខរដ្ឋ ចូលរួម ក្នុងពិធីនេះ។ ម្យ៉ាងទៀត ក្នុងឆ្នាំ១៩៦៨ ព្រះអង្គ លើក

53 សន្ធ្យាកាល= Déclin, crépuscule។
54 អង្គការ សន្ធិសញ្ញា អាស៊ី បែក អគ្នេយ៍= O.T.A.S.E. (SEATO)។
55 អនត្ថការ= Sabotage។

ដំកើង ស្ថានតំណាង រដ្ឋាភិបាល ប្រជាធិបតេយ្យ វៀតណាមខាងត្បូង (វៀតកុង) ជាស្ថានឯកអគ្គរដ្ឋទូត ; ទង្វើនេះ គឺជា ការទទួលស្គាល់ ជា ផ្លូវការ នៃរដ្ឋាភិបាល នេះ លើឆាកអន្តរជាតិ។ សួរថា តើ អាកប្បកិរិយា របស់ព្រះអង្គ បែបនេះ ជា នយោបាយ ស្វែងរក **សមតាកម្ម**[56] រវាង លោក សេរី ជាមួយនឹងលោក កុម្មុយនិស្ត ឬ ?

ដូចបានជំរាប ខាងលើថា នយោបាយ អន្តរជាតិ របស់ សម្តេច សីហនុ គឺ ផ្អែកលើ អព្យាក្រឹតភាព ដូច្នេះ យើងលើកយក ចំណុចនេះមកពិនិត្យ ថាតើ វាមាន លក្ខណៈបែបណា និង មានការពិត ដែរឬទេ ?

## ១. អព្យាក្រឹតភាព ជាមួយនឹង បស្ចឹមលោក

អព្យាក្រឹតភាព របស់ សម្តេច សីហនុ វា **វិសមិត**[57] ជាមួយនឹង សង្គ្រាម នៅវៀតណាម ហេតុនេះឯង បានជា សហរដ្ឋអាមេរិក មិនដែលទទួល ស្គាល់ អព្យាក្រឹត នេះឡើយ ដែលនាំបង្កើតជាទំនាស់ រវាង សីហនុ ជាមួយ សហរដ្ឋអាមេរិក។ ទំនាស់ នេះ មានពីរដំណាក់៖ ទី១. ការឈប់ទទួល ជំនួយ អាមេរិកាំង ក្នុងឆ្នាំ ១៩៦៤ ; ទី២. ការកាត់ចំណងទូត រវាង ប្រទេសទាំងពីរ ដែលចាត់ទុកបានជា វិបត្តិ នយោបាយទូត សំខាន់ រវាង កម្ពុជា ជាមួយនឹង សហរដ្ឋអាមេរិក។ សម្តេច សីហនុ ជាអ្នកបង្កើត វិបត្តិ នេះ ក្នុងគោលបំណង ដូរទិស នយោបាយ ក្រៅប្រទេសរបស់ព្រះអង្គ គឺ បែរ ទៅរក លោក កម្មុយនិស្ត ជាពិសេស ចិនប្រជាមានិត។ ចាប់ពីពេលនេះមក អព្យាក្រឹតខ្មែរ វា ផ្អៀង ដែលនាំឲ បស្ចឹមប្រទេស ទុក អព្យាក្រឹតខ្មែរ សំរាប់តែ បំរើ ប្រយោជន៍ កុម្មុយនិស្ត នៅតណ្ហូចិន តែប៉ុណ្ណោះ។

ដើម្បី ជៀសវាង ការចោទប្រកាន់នេះ សម្តេច សីហនុ យក ប្រទេសបារាំង ជាមិត្ត ទី១ របស់ខ្មែរ ក្នុងបណ្តា បស្ចឹមប្រទេស ដែលជា ប្រទេស ផ្តល់ នូវ គំរូ សេរី។ ថែមទៅទៀត ព្រះអង្គបង្កើតទ្រឹស្តីថ្មី ដើម្បីការពារ អព្យាក្រឹត គឺ ទ្រឹស្តី **បដិការ**[58] ដោយលើកយក ប្រធានបទ ការគោរពព្រំដែនខ្មែរ ពីសំណាក់ អាមេរិកាំង វៀតណាម ខាងត្បូង និង ខាងជើង ហើយនិង ថៃ ជា ល័ក្ខខ័ណ្ឌ ខានមិនបាន ដើម្បី ឲ ព្រះអង្គ ប្រតិបត្តិ បានស្រួល នូវ **អព្យាក្រឹតនិយម ស្មើគ្នា**[59] ក្នុងដំបន់សង្គ្រាម មួយ ដែលមាន លោក សេរី ហើយនឹង លោក កម្មុយនិស្ត ជា អ្នកផ្តល់ អាវុធយុទ្ធភ័ណ្ឌ  ដល់ យុទ្ធការី នៅលើ សមរភូមិ។ ទុកណា សីហនុ ប្រើ យុទ្ធសាស្រ្តថ្មី តែ ទ្រង់ គ្មាន ឆន្ទៈពិតប្រាកដ ប្តឹង ទៅ គណកម្មាធិការ អន្តរជាតិ ត្រួតពិនិត្យ (C.I.C.) កិច្ចព្រមព្រៀង ទីក្រុងGenève អំពី ការតាំង ទីទ័ព យួនកម្មុយនិស្ត នៅក្នុង ស្រុកខ្មែរ ដូចព្រះអង្គ ធ្លាប់ប្តឹង ទៅក្រុមព្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ អំពី ការឈ្លានពាន ទ័ពអាកាស អាមេរិកាំង និងកងកម្លាំង យួនខាងត្បូង មកក្នុងស្រុកខ្មែរ។

## ២. អព្យាក្រឹតភាព ហើយនឹង ការធានា អន្តរជាតិ

56 សមតាកម្ម= Equilibrage។
57 វិសមិត= មិនត្រូវគ្នា ; Incompatible។
58 បដិការ= ភាពមានទៅវិញទៅមក ; Réciprocité។
59 អព្យាក្រិតនិយម ស្មើគ្នា= Neutralisme égalitaire។

នៅពេលនោះ គណកម្មាធិការ អន្តរជាតិ ត្រួតពិនិត្យ (**គ.អ.ត.**) អាចទុកជា **ភោគប្រយោជន៍**[60] មួយ សំរាប់ ការពារ អព្យាក្រឹតភាពខ្មែរ តែបែរ ជា សម្តេច សីហនុ ទុកជា បញ្ហា សំរាប់ ព្រះអង្គទៅវិញ។ ក្នុងចំណុចនេះ សហរដ្ឋអាមេរិក ធ្លាប់ បញ្ជាក់[61] នៅចំពោះមុខ ក្រុមព្រឹក្សា សន្តិសុខ នៃអង្គការ សហប្រជាជាតិ ថា អព្យាក្រឹតភាព ខ្មែរ **គ្មានភាពជាប់ស្និទ្ធគ្នា**[62] សោះ ព្រោះថា ប្តឹង អំពី ការឈ្លានពាន អាមេរិកាំង ទៅ អង្គការ សហប្រជាជាតិ តែមិនព្រមឲ **គ.អ.ត.** ត្រួតពិនិត្យ អំពី ការតាំងទីទ័ពវៀតកុង នៅក្នុងស្រុកខ្មែរ។ ទាល់ច្រក ចំពោះ ការសង្កេតនេះ សម្តេច សីហនុ **តាង**[63] ធ្វើតាម ឱវាទ នេះ បែរជាសុំឲ អង្គការសហប្រជាជាតិ កោះប្រជុំ កិច្ចព្រមព្រៀង នៅទីក្រុង Genève ជាថ្មី ទៅវិញ។ តាម ការស្នើ ពីប្រទេស Côte d'Ivoire អង្គការ សហប្រជាជាតិ សំរេច បង្កើត បេសកកម្ម មួយ មានសមាជិកបីរូប ទៅស៊ើបអង្កិត ក្នុងទឹកដីខ្មែរ នៅទីន្លែង ដែលខ្មែរចោទប្រកាន់ថា កងកម្លាំង យួនខាងត្បូង ចូលមកក្នុងដីខ្លួន។ បេសកកម្ម នេះ មានរយៈពេល ៤៥ថ្ងៃ ដើម្បី ធ្វើសេចក្តីរាយការណ៍ ជូនដល់ អង្គការសហប្រជាជាតិអំពី ទំនាស់នេះ។ ក្រោយ ពីបាន ពិនិត្យ ទីកន្លែង និង ស្តាប់ សេចក្តីសំអាង របស់ ភាគីទាំងសងខាងរួច គេបាន ធ្វើសេចក្តីរាយការណ៍ ដែលមានខ្លឹមសារ ថា ភាគីទាំងពីរ ទទួលខុសត្រូវ ស្មើគ្នា ព្រោះ វៀតណាមខាងត្បូង គ្រាន់តែ ប្រើសិទ្ធិ ដេញតាម ពួកវៀតកុងរត់ចូលស្រុកខ្មែរ ក្រោយពីបាន វាយប្រហារ ខ្លួន។ ចាប់ ពីពេលនោះមក អង្គការសហប្រជាជាតិ ទុក អព្យាក្រឹតភាពខ្មែរ ជា នយោបាយផ្ទាល់របស់ ខ្មែរ តែប៉ុណ្ណោះ ដូច្នេះ គ្មានការទទួលស្គាល់ ពីខ្លួន នោះឡើយ។ ហើយ បេសកកម្ម **គ.អ.ត.** មាន ភារៈកិច្ច ត្រឹមតែ ពិនិត្យមើល ការឈប់បាញ់គ្នា និង កុំឲមាន ទីតាំង កងទ័ព បរទេស នៅក្នុង ទឹកដី ខ្មែរ តែប៉ុណ្ណោះ។ នៅត្រង់ចំណុចនេះឯងហើយ ដែល ជា កង្វល់ របស់ សម្តេច សីហនុ ព្រោះ ព្រះអង្គបានអនុញ្ញាត តាមការស្នើរបស់ចិនប្រជាមានិត ឲទ័ព យួនកុម្មុយនិស្ត តាំងទី នៅក្នុង ស្រុកខ្មែរ ហេតុនេះឯងបានជា ព្រះអង្គ សំរេច ព្យួរ បេសកកម្ម **គ.អ.ត.** ក្នុងឆ្នាំ ១៩៦៩ ដែលនាំឲខូចប្រយោជន៍ដល់ប្រទេសខ្មែរ។

យើងអាច សន្និដ្ឋានបានថា នៅក្នុងឆ្នាំ ១៩៧០ ស្ថានការណ៍ នយោបាយ នៅស្រុកខ្មែរ ទាំងក្នុងប្រទេស ហើយនឹង លើឆាក អន្តរជាតិ វាទុំ សំរាប់ បំលាស់ប្តូរ របបនយោបាយមួយ ដែលលែងមាន សម្កភាព ការពារ ប្រយោជន៍ ប្រជាជាតិ ដូចផ្លែឈើទុំ ហើយ ធ្លាក់ពីមែក នោះឯង។

បន្ទាប់មកទៀត យើងលើកយក ចំណុច ពិភាក្សា អំពី ការទម្លាក់ សម្តេច សីហនុ ដែលមានចោទជាបញ្ហា ថាតើជា រដ្ឋប្រហារ ឬ ស្របច្បាប់រដ្ឋធម្មនុញ្ញ មក ពិនិត្យ ដូចខាងក្រោមនេះ។

## លើឋាន រដ្ឋធម្មនុញ្ញ

### ១. ចោទជាបញ្ហា

60 ភោគប្រយោជន៍= Atout។

61 ពញ្ញាក់ដោយ លោក Stevenson, ប្រតិភូ សហរដ្ឋអាមេរិក នៅ អង្គការសហប្រជាជាតិ នៅកំឡុងខែមិថុនា-កក្កដា ឆ្នាំ ១៩៦៤។

62 គ្មានភាពជាប់ស្និទ្ធគ្នា= Incohérence។

63 តាង= Au lieu de។

យើងយក ក្រម (ច្បាប់) លេខ ៣៩០ ឆ្នាំ ១៩៦០ (១៤ មេសា) ចារក្នុង រដ្ឋធម្មនុញ្ញ ក្នុង មាត្រា ១២២ ស្តីអំពី ស្ថាប័ន «ប្រមុខរដ្ឋ» មកពិនិត្យ៖

*«នៅក្នុង កាលៈទេសៈ ណាមួយ ដែល មិនអាច តែងតាំង ព្រះមហាក្សត្រ និង ក្រុមព្រឹក្សា រាជានុសិទ្ធិ បាន, ស្របតាម បទបញ្ញត្តិ នៃ មាត្រា ៣០ និង ៣០ ស្ទួន នៃរដ្ឋធម្មនុញ្ញ បច្ចុប្បន្ន សភាទាំងពីរ ប្រជុំគ្នា តាមការកោះអញ្ជើញ ពី ប្រធានរដ្ឋសភា និង ក្រោម អធិបតីភាព របស់ លោក ស្របតាម ការសំដែងឆន្ទៈ ពី ប្រជាពលរដ្ឋ, ប្រគល់ គ្រប់អំណាច និង បុព្វសិទ្ធិប្រមុខរដ្ឋ ដល់តស្សូរជន ដែលគេយល់ព្រមទាំងអស់គ្នា, ហើយជ្រើសតាំង ដាច់ខាត តស្សូរជននេះ ជា ប្រមុខរដ្ឋ តាមការបោះឆ្នោត នៃប្រជាជាតិ។*

*ហើយមុននឹង ទទួលបន្ទុក អំណាច, ប្រមុខរដ្ឋ តស្សូរជន នេះ ត្រូវធ្វើសច្ចាប្រណិធាន នៅមុខ រដ្ឋសភា ស្របតាម មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ ដោយ ប្រកាសថា "ខ្លួន ស្មោះត្រង់នឹង រាជបល្ល័ង្គ"»*

យើងឃើញច្បាស់ថា សភាជា អ្នកតែងតាំង ប្រមុខរដ្ឋ ស្របតាម ការសំដែងឆន្ទៈ ពី ប្រជាពលរដ្ឋ តាមការបោះឆ្នោត នៃប្រជាជាតិ តែ ក្នុងមាត្រា ១២២ មិនមាន ចែង អំពី រយៈពេល អាណត្តិ និង ការទទួលខុសត្រូវ ព្រហ្មទណ្ឌ របស់ ប្រមុខរដ្ឋ, ការលាលែងពីដំណែង ដោយថាហេតុ ដោយខ្លួនឯង ឬ តាមការបង្ខំ , ការហូតងារ ឬ យកទៅវិនិច្ឆ័យ។ តែ អវត្តមាន នេះ មិនមាន ន័យថា ប្រមុខរដ្ឋ ជាដំណែង គ្មាន ការទទួលខុសត្រូវ ចំពោះមុខសភា និង ការមិនអាចហូត ងារបាន ពីសំណាក់ សភា នោះដែរ។

ការគ្មានភាពអ្វីពិតប្រាកដ នេះ កើតមក ពីការធ្វើច្បាប់មួយ សំរាប់ បុគ្គល សីហនុ តែមួយ គត់ ដែលទ្រង់ខ្លួនឯង បង្កើតវា សំរាប់ ដោះស្រាយបញ្ហាផ្ទាល់ របស់ខ្លួន គឺមិនហ៊ាន ឡើង គ្រោងរាជសម្បត្តិ ឡើងវិញ ក្រោយពី បិតា ស្តេចសុគតទៅ ព្រោះខ្លាចចាញ់សម្បថ។ តាមពិត ទ្រង់ ឡើងកាន់ដំណែង មុន ការតែងច្បាប់ រួចស្រេចទៅហើយ ក្រោយពីមាន ប្រជាបាតុកម្ម សុំ ឲព្រះអង្គ ទទួលដំណែង ព្រះប្រមុខរដ្ឋ។ ដើម្បី សម្របនឹង អំពើនេះ ប្រធានរដ្ឋសភា គ្រាន់តែ ធ្វើការប្រកាសជាឧឡារិក ប្រគល់ ដំណែងនេះ ថ្វាយព្រះអង្គ។ ដូច្នេះ មាត្រា ១២២ គ្រាន់តែជា **និយតកម្ម**[64] នៃហេតុការ ដែលមានកើតឡើង ដើម្បី ធ្វើ រដ្ឋធម្មនុញ្ញ **ឲត្រូវនឹងការបង្ខំ**[65] របស់ សីហនុ តែប៉ុណ្ណោះ។

ការហូតងារ សម្តេច សីហនុ ពីសំណាក់ សភា នៅថ្ងៃទី ១៨ មីនា គ្មានលក្ខណៈណា ដែលទុកជាទ ង្វើខុសច្បាប់ រដ្ឋធម្មនុញ្ញ ព្រោះ ធ្វើឡើង តាម ការសំដែងឆន្ទៈ ពី ប្រជាពលរដ្ឋ តាមប្រជា បាតុកម្ម ប្រឆាំងនឹង នយោបាយ របស់ សម្តេច សីហនុ អនុញ្ញាតឲ ទ័ពយួនវៀតកុងតាំង ជុំរុំ នៅក្នុងស្រុកខ្មែរ។ ដើម្បី រកដំណោះស្រាយនឹង បញ្ហានេះ បបាតុករ បានសុំឲរដ្ឋសភាយក បញ្ហានេះ ទៅពិនិត្យ ជា បន្ទាន់។ ក្រោយពី បរាជ័យ ស្វែងរក ដំណោះស្រាយជាមួយ សីហនុផ្ទាល់ នាំឲសភាជាតិ បោះឆ្នោត ជាឯកច្ឆន្ទ ហូតងារ ព្រះអង្គ ពីដំណែង ព្រះប្រមុខរដ្ឋ ដើម្បី ដោះ ស្រាយបញ្ហាអាយុជីវិតជាតិ។

64 និតតកម្ម= ធ្វើឲស្របច្បាប់ ; Régularisation។
65 ឲត្រូវនឹងការបង្ខំ= Diktat។

## ២. ប្រតិកម្ម របស់ សម្តេច សីហនុ

ថ្ងៃទី ២០ មីនា ឆ្នាំ ១៩៧០ សម្តេច សីហនុ ធ្វើ សេចក្តីថ្លែងការណ៍ មួយ ទុក ការហូតងារ ព្រះអង្គ ជាទង្វើ ខុសច្បាប់ ដូចមានសេចក្តី ជាសង្ខេប ខាងក្រោមនេះ៖

*«ខ្ញុំ សុំឲ សារព័នមាន យកចិត្តទុកដាក់ នូវលើព្រឹត្តិការណ៍ដូចតទៅ៖ ការទំលាក់ខ្ញុំ តាមការ ប្រកាស នៃរដ្ឋសភា និង ក្រុមព្រឹក្សា ព្រះរាជាណាចក្រខ្មែរ គឺ ឥតស្របច្បាប់ ដាដាច់ខាត តាម ហេតុ ដូចតទៅនេះ : ខ្ញុំ ត្រូវបាន តែងតាំង ជាប្រមុខរដ្ឋ ក្នុងឆ្នាំ ១៩៦០ ដោយសភា (បោះ ឆ្នោតជាឯកច្ឆន្ទ) ស្របតាម បទបញ្ញាតិ នៃរដ្ឋធម្មនុញ្ញ នៃរាជាណាចក្រ។ ខ្ញុំ បានស្បថ នៅ ចំពោះមុខសភា ស្របតាម បទបញ្ញាតិ នៃរដ្ឋធម្មនុញ្ញ ដែរ។ ដូច្នេះ ការអះអាង ពីសំណាក់ សមាជិក រដ្ឋសភា ខ្លះ ថា ខ្ញុំ ឡើងកាន់ ដំណែង ជាន់ខ្ពស់ នៃរដ្ឋ នេះ ពី ប្រជាបាតុកម្ម ធម្មតា ជា ការអះអាង ខុស ស្រឡះ។*

*ផ្ទុយទៅវិញ នៅក្នុងរដ្ឋធម្មនុញ្ញយើង ក៏ដូចគ្នា ក្នុង វិសោធនកម្ម ថ្មីៗ មុន ថ្ងៃ រដ្ឋប្រហារ ខុស ច្បាប់ រដ្ឋធម្មនុញ្ញ ក្នុងខែ មីនា ឆ្នាំ ១៩៧០ ដែលធ្វើឡើង ដោយ ពួក ស្តាំនិយម ជ្រុលហួស នៅ ភ្នំពេញ វាគ្មានបទបញ្ញាតិ ណាមួយ ដែល អនុញ្ញាត ឲ រដ្ឋាភិបាល ទំលាក់ប្រមុខរដ្ឋ ដែលបាន តែងតាំង អស់មួយជីវិត ហើយលក្ខណ:អស់មួយជីវិតនេះ គឺធ្វើតាមការសំដែងចិត្ត ពិត ប្រាកដមែន។*

*ដូច្នេះ មានតែ ប្រជាជាតិ ទេ ដែលអាច ទំលាក់ ខ្ញុំ ពីដំណែងនេះបាន គឺថា តាម ប្រជាមិតិ ដែលជាវិធីត្រឹមត្រូវមួយ ស្របតាមរដ្ឋធម្មនុញ្ញ ដែលគ្មាននរណា អាចប្រកែកបាន។ តែបើ សិន មានប្រជាមិតិ រៀបចំឡើង ពី សំណាក់ រដ្ឋាភិបាល ក្បត់ និង បំពានសម្បថ ដែលខ្ញុំ ជា អ្នកស្នើ ឲរដ្ឋសភាបោះឆ្នោត ដែលជារដ្ឋសភា ក្បត់ និង បំពានសម្បថ ដែរ មានតំណាងរាស្ត្រ ជា សមាជិកក្រោមទង់* ***សង្គម*** *ដែលមានខ្ញុំជាប្រធានចលនា ហើយខ្ញុំ មានប្រជារាស្ត្រ មានសេចក្តី ស្មោះត្រង់នឹងខ្ញុំ មិនអាចសាបសូន្យទៅបាន នៅក្នុងករណីបែបនេះ ខ្ញុំនឹងទុក ប្រជាមិតិ នេះ គ្មានតម្លៃ អ្វីឡើយ....។*

## 3. ចម្លើយ រដ្ឋាភិបាល ភ្នំពេញ

ថ្ងៃទី ៥ មេសា ឆ្នាំ ១៩៧០ ទីស្តីការ ក្រសួង ឃោសនាការ ធ្វើសេចក្តីថ្លែងការណ៍ បញ្ជាក់ជាផ្លូវការ នូវហេតុផល នៃការទំលាក់ សម្តេច សីហនុ ពីដំណែង ព្រះប្រមុខរដ្ឋ មានសេចក្តី ជាសង្ខប ដូច តទៅ៖

«បន្ទាប់ពីមាន ប្រជាបាតុកម្ម នៅក្នុងឆ្នាំ១៩៦០, សម្តេច សីហនុ ត្រូវបាន តែងតាំង ជា ព្រះ ប្រមុខរដ្ឋ តាមការប្រកាស របស់ ប្រធានរដ្ឋសភា ក្នុងកិច្ចប្រជុំ ជាសារណ: ដោយគ្មានមានការ បោះឆ្នោត អ្វីនោះឡើយ។ ក្រោយពីបានធ្វើប្រកាសរួច សមជិក សភាជាតិ គ្រាន់តែនាំគ្នា ទះ ដៃ សរសើរ តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ព្រឹត្តិការណ៍ ថ្ងៃទី១៨មីនា បន្ទាប់ពីមានបាតុកម្ម ប្រឆាំង នឹង សីហនុមក សមជិក សភាជាតិ បានធ្វើការបោះឆ្នោត ជាសាធារណ: នៅកន្លែង វេទិកា រដ្ឋ សភា សំរេច ហូតងារ សម្តេច សីហនុ ពីមុខដំណែង ដែលមាន ៩២ សម្លេង បោះហូតងារ ក្នុង ចំណោម អ្នកបោះឆ្នោត ៩២នាក់។ ឯចំណែក នីតិវិធី ទំលាក់ នេះទៀត វាស្របគ្នា និង នីតិវិធី

តែងតាំង គ្រាន់តែ នីតិវិធី ហូតងារ វាមានលក្ខណៈច្បាប់រ៉ឹងប៉ឹង ជាង នីតិវិធិ តែងតាំង ព្រោះ មានការបោះឆ្នោតជាសម្ងាត់ នៅទីកន្លែង វេទិការ ដែលបញ្ជាក់ ថា វា ជានីតិវិធី ស្របច្បាប់។

**ដោយអាស្រ័យលើច្បាប់ នូវសណ្ឋាន នៃភាពស្របនិយម**[66] វិធានណាមួយ ដែលសភាមួយ ធ្លាប់ បានធ្វើ, សភាមួយទៀត ក៏អាចធ្វើ បានដែរ។ ដូច្នេះ សភា នៅឆ្នាំ ១៩៦០ តែងតាំង សម្តេច សីហនុ ជា ប្រមុខរដ្ឋ, សភា បច្ចុយប្បន្ន ក៏អាច ហូតងារ ព្រះអង្គ វិញបានដែរ។ ដូច្នេះ វាមិនចំ បាច់មាន បទបញ្ញាតិ អ្វីនោះទេ ក្នុង វិធី ហូតងារនេះ។ ព្រោះថា នៅក្នុង រដ្ឋធម្មនុញញខ្មែរ ឆ្នាំ ១៩៤៧, មានតែ ព្រះមហាក្សត្រ មួយគត់ ដែល តែងតាំងឡើង អស់មួយជីវិត។ ហើយ នៅពេល ដែល រាជបល្ល័ង្ក នៅភាពទំនេរ ក្រុមព្រឹក្សា រាជសម្បត្តិ ត្រូវជ្រើសរើស ព្រះមហាក្សត្រ ថ្មី (មាត្រា ៣០)។ នៅក្នុង កាលៈទេសៈ ណាមួយ ដែល មិនអាចតែងតាំង ព្រះមហាក្សត្យ បាន ក្រុមព្រឹក្សា រាជសម្បត្តិ ត្រូវ បោះឆ្នោត ជ្រើសរើស ក្រុមព្រឹក្សា រាជានុសិទ្ធិ ដើម្បី ទទួល កាន់កាប់ ជា បណ្តោះអាសន្ន រាជាបុព្វសិទ្ធិ (មាត្រា ៣០ ស្ទួន)។ បើពុំអាចជ្រើសរើស ក្រុម ព្រឹក្សា រាជានុសិទ្ធិ បាន ទើប ត្រូវជ្រើសរើស ប្រមុខរដ្ឋ ដើម្បីជំនួស ក្រុមព្រឹក្សានេះ (មាត្រា ១២២)។ ដូច្នេះ ប្រមុខរដ្ឋ គ្រាន់តែជំនួស ក្រុមព្រឹក្សា រាជានុសិទ្ធិ ជាបណ្តោះអសន្នតែ ប៉ុណ្ណោះ។ ហេតុនេះ ប្រមុខរដ្ឋ គ្មានសិទ្ធិលើសពីក្រុមព្រឹក្សារាជានុសិទ្ធិ ដែលខ្លួន ជំនួស នោះ ទេ។ តែបើ ប្រមុខរដ្ឋ ទាមទារ សិទ្ធិ ជា បុគ្គលពិសិដ្ឋ មិនអនុញ្ញាតឲរំលោភលើខ្លួនបាន ហើយ កាន់ដំណែងអស់មួយជីវិតដូចព្រះមហាក្សត្រ បុគ្គលនេះ គេទុកជា អ្នកដណ្តើមរាជ្យ ឬអំណាច នោះឯង។

បើយោងតាម រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ (មាត្រា ៣០ស្ទួន) អាណត្តិ របស់ ប្រមុចរដ្ឋ មានរយៈស្មើ និង ការតែងតាំង ក្រុមព្រឹក្សា រាជានុសិទ្ធិ គឺ រយៈពេល **អង្គនីតិបញ្ញត្តិ**[67] (៤ឆ្នាំ) តែប៉ុណ្ណោះ។ ដូច្នេះ តាម **តក្ក**[68] រដ្ឋធម្មនុញ្ញ, ប្រមុខរដ្ឋ ត្រូវតែជ្រើសរើស តាមការបោះឆ្នោត នៅដើម រយៈ ពេល អង្គនីតិបញ្ញត្តិ និមួយៗ។ នៅត្រង់ចំណុចនេះឯង ដែល សម្តេច សីហនុ បំពានច្បាប់ ដូច្នេះ ព្រះអង្គ អស់មានងារ ជាព្រះប្រមុខរដ្ឋ តាំងពីឆ្នាំ ១៩៦៥ មកម្លេះ ព្រោះព្រះអង្គមិនបាន តែងតាំងជាថ្មីតាមការបោះឆ្នោត ពីសំណាក់ អង្គនីតិបញ្ញាត្តិ ថ្មី។ តាំងពីឆ្នាំ១៩៦៥ ព្រះអង្គ កាន់ដំណែងឥតស្របច្បាប់ មិនតែប៉ុណ្ណោះ គឺ ព្រះអង្គ គ្មានសមត្ថភាព ថែមទៅទៀត។

សម្តេច សីហនុ សន្មត់ថា មានតែ វិធី ប្រជាមតិទេ ទើបអាច ទំលាក់ ព្រះអង្គ ពីមុខដំណែងបាន។ ក្នុង រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ ១៩៤៧ ប្រជាមតិ អាចប្រព្រឹត្ត នៅក្នុង ករណី ណា ដែល រដ្ឋសភា និង សាមាជជាតិ មាន ការខ្វែងយោបល់គ្នា ហើយនៅ ក្នុង ករណី នេះទៀត គឺមានតែ រដ្ឋសភា តែមួយគត់ ជាអ្នក ប្រកាសធ្វើ ប្រជាមតិ លើបញ្ហា ដើម្បីដាក់ជូនឲ សមាជជាតិ ឲធ្វើការ សម្រេច តាមលទ្ធផល នៃប្រជាមតិ។ ម៉្យាងទៀត តាម ច្បាប់ ព្រហ្មទណ្ឌ, សម្តេច សីហនុ អាច នឹងទទួលទោសបទឧក្រិដ្ឋ ព្រោះទ្រង់បានបំពាន រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រ ដូចមាន ចែងនៅ ក្នុងមាត្រា ២២១ នៃ ក្រមព្រហ្មទណ្ឌថា **ឧបឃាត**[69] ណាមួយ ដែលមាន គោល បំណង ដូរ ឬ បំផ្លាញ រដ្ឋធម្មនុញ្ញ ត្រូវ ទទួលទោសបទឧក្រឹដ្ឋ ថ្នាក់ទី៣។

---

66 ដោយអស្រ័យលើច្បាប់ នូវសណ្ឋាន នៃភាពស្របនិយម= En vertu de la règle du parallélisme des formes។
67 អង្គនីតិបញ្ញត្តិ= អាណត្តិ របស់ រដ្ឋសភា ; Législature។
68 តក្ក= សមហេតុសមផល ; Logique។
69 ឧបឃាត= Attentat។

យ៉ាងណាម៉េច សម្តេច សីហនុ មិនដែល គោរព រដ្ឋធម្មនុញ្ញ និង ច្បាប់ នៃព្រះរាជាណាចក្រ ដូចយ៉ាងងអនុញ្ញាត ឲ នគបាល ចាប់ពលរដ្ឋខ្មែរជាច្រើន យកទៅសម្លាប់ចោលគ្រាន់តែមានមន្ទិលសង្ស័យ ថាជនទាំងនោះ ជាខ្មែរក្រហម តែប៉ុណ្ណោះ។ អំពើបែបនេះ ជាការបំពាន បទបញ្ញាតិនៃរដ្ឋធម្មនុញ្ញ ដែលធានា សេរីភាព ពលរដ្ឋ និង សុវត្ថភាព សាធារណៈ។ ឧបឃាត របស់ សីហនុ ប្រឆាំងនឹង រដ្ឋធម្មនុញ្ញ បានប្រព្រឹត្តិ ជាក់ស្តែង រួចទៅហើយ ដូច្នេះ វាមិនមែនជាពេលវេលា ត្រូវយកច្បាប់មក បកស្រាយ នោះឡើយ ផ្ទុយទៅវិញ ជាពេលវេលា យកច្បាប់មកអនុវត្តិ ដាក់ទណ្ឌកម្ម ដល់ជន ដែលបានប្រព្រឹត្តិ អំពើល្មើសច្បាប់ តែប៉ុណ្ណោះ។ អវត្តមាន នៃជនជាប់ចោទនេះ មិនអាចដូរធាតុ នូវកំហុសដែលជននេះ បានប្រព្រឹត្ត នោះបានឡើយ។

សម្តេច សីហនុ ញុះញង់ ឲទ័ពវៀតកុង ឈ្លានពាន ស្រុកខ្មែរ ហើយ ឆុងឆាំង ប្រឆាំងនឹងការប្រកាស ជាតិមានអាសន្ន។ ទ្រង់ ដេញ **គ.អ.ត.** ចេញពីស្រុកខ្មែរ ព្រោះមិនចង់ឲគណកម្មាធិការនេះ មើលឃើញ វត្តមាន កងទ័ព វៀតកុង នៅក្នុងស្រុកខ្មែរ។ ទង្វើនេះ ដែលនាំ សភាជាតិ និង រដ្ឋាភិបាល តម្រូវ ចាត់វិធានការទប់ទល់នឹង ហានិភ័យ នេះ ហើយ ប្រកាស ជាតិមានអាសន្ន។ ចរិតបែបនេះហើយ ដែល សម្តេច សីហនុ ថា ព្រះអង្គ ជាអ្នកស្នេហាជាតិ, ស្នេហាសន្តិភាព, ស្នេហាចិរភាពនយោបាយ, ស្នេហាច្បាប់ និង យុត្តិធម៌។

## សេចក្តសន្និដ្ឋាន

ទស្សនៈ សម្តេច សីហនុ ហើយនិង រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ដែលលើកមកបរិយាយខាងលើនេះ ជា ការជជែកតវ៉ា ជាសាធារណៈ នៃគូរវិវាទ ដែលយើងទុកឲ ខ្មែរបច្ចុប្បន្ន យកទៅពិចារណា អំពី ធាតុ នៃព្រឹត្តិការណ៍ ១៨ មីនា ឆ្នាំ ១៩៧០ ថា ជាធាតុ រដ្ឋប្រហារ ប្រឆាំង សម្តេច សីហនុ ឬ ជា ការហូតងារ ព្រះអង្គ ស្របតាមច្បាប់ រដ្ឋធម្មនុញ្ញ។ ចំពោះយើងវិញ, យើង គ្មានការស្ទាក់ស្ទើនៅក្នុង**គតិ**[70] របស់យើងនោះឡើយ ព្រោះយើងទុក ការហូតងារ សម្តេច សីហនុ ពីដំណែង ប្រមុខរដ្ឋខ្មែរ ជាប្រតិកម្ម នៃ ប្រជាជាតិខ្មែរ ប្រឆាំងនឹង អំពើក្បត់ជាតិ របស់ ព្រះអង្គ។ ប្រតិកម្ម នេះ មានឡើង ក្នុង គ្រោងច្បាប់ រដ្ឋធម្មនុញ្ញ ហើយនិង គតិ អហឹង្សា ស្របតាមចរិតខ្មែរ ជាអ្នកកាន់ពុទ្ធសាសនា ដែលជាសាសនា ស្រឡាញ់ សន្តិភាព។ តែយើងដឹងថា សម្តេច សីហនុ យកការសងសឹក ជាកំហឹង បង្កើត សង្គ្រាម នៅក្នុងស្រុកខ្មែរ អនុញ្ញាតឲ ទ័ពវៀតកុង កុម្មុយនិស្ត វាយកងទ័ពជាតិខ្មែរ ដើម្បី ដណ្តើមអំណាច តែប៉ុណ្ណោះ។ យើងដឹងថា ចំណង់នូវអំណាច និង សងសឹក របស់ សម្តេច សីហនុ នេះ មានផលប៉ះពាល់អាក្រក់ ដល់ជាតិខ្មែរ នាំប្រទេសខ្មែរ បច្ចុប្បន្ន ក្លាយ ជា ប្រទេសអាណានិគម វៀតណាម ដែលមាន របបរាជានិយម ជា **សំចោរ**[71] មាន គណបក្សប្រជាជន និង គណបក្សសង្គ្រោះជាតិ ដែលជាគណបក្ស បាវបំរើ ប្រយោជន៍យួន ជា ឧបករណ៍ យួន សំរាប់ និគ្រោះ ប្រជាជនខ្មែរ។

ថ្ងៃទី ៣ មីនា ឆ្នាំ ២០១៥

ឧប សៅ សង្ខា

---

[70] គតិ= Esprit។
[71] សំចោរ= ចូលដៃ ; Complice។